ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# <u>កិច្ចព្រមព្រៀងរវាង</u>

## រោងចក្រ ហ្គ្រេត យូញៀន (ខេមបូឌា) ហ្គាមេន លីមីធីត និង តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋាន ប្រចាំរោងចក្រ ហ្គ្រេត យូញៀន (ខេមបូឌា) ហ្គាមេន លីមីធីត

## <u>ស្តីពីការព្យួរកិច្ចសន្យាការងារ</u>

នៅថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០២៣ វេលាម៉ោង ១០ និង០០នាទី ព្រឹក នៅរោងចក្រមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅរោងចក្រដោយសារតែគ្មានការបញ្ជាទិញទីភ្ញៀវ ហេតុនេះហើយទើបធ្វើអោយរោងចក្រទាំងមូលត្រូវផ្អាក់ដំណើរការរយៈពេល ២ខែបន្តទៀត គឺចាប់ពី ថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ២០២៣ដល់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២៣ សំរាប់កម្មករទាំងអស់......៦៧៥.....នាក់(ស្រី..៦០៦...នាក់)។ ដោយក្នុងកំឡុងព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុននឹងផ្តល់អត្ថប្រយោជន៍ដោយឯកភាពដូចខាងក្រោម:

1. ចំនួន ១៥ដុល្លារ សំរាប់ព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ ថ្ងៃ។
2. ចំនួន ៣០ដុល្លារ សំរាប់ព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ ខែ។
3. ការបើកប្រាក់ចំនួន ៣០ ដុល្លារ នៅថ្ងៃទី២៥ រៀងរាល់ខែ។

កម្មករទាំងអស់ត្រឡប់មកបំពេញការងារវិញនៅថ្ងៃចន្ទ ទី០១ ខែ មករា ឆ្នាំ២០២៤ វិញ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១និង០០នាទី នាថ្ងៃខែឆ្នាំ ដដែល ដោយភាគីទាំងអស់មានភាពស្និតស្នាលនិងការយោលយោគគ្នាក្រោមស្មារតីទទួលខុសត្រូវនិងសហការគ្នាយ៉ាងរលូន។

ភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២៣

តំណាងកម្មករនិងតំណាងសហជីព

នាយកក្រុមហ៊ុន

GREAT UNION(CAMBODIA)GARMENT Co.,Ltd.

# ស្នាមមេដៃ

## តំណាងកម្មករ ប្រធានក្រុម តំណាងសហជីព

